**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**អគ្គនាយកដ្ឋាននយោបាយ និងកិច្ចការបរទេស**
**នាយកដ្ឋានកិច្ចការអាស៊ាន**
លេខ: ០៤/២០២២

# សេចក្តីប្រកាសព័ត៌មាន
## ស្តីពីលទ្ធផលនៃកិច្ចប្រជុំក្រុមការងារឧត្តមមន្ត្រីការពារជាតិអាស៊ាន

កាលពីថ្ងៃ០៧-០៨ ខែកុម្ភៈ ឆ្នាំ២០២២ អគ្គនាយកដ្ឋាននយោបាយ និងកិច្ចការបរទេស ក្រសួងការពារជាតិ បានរៀបចំនូវកិច្ចប្រជុំក្រុមការងារឧត្តមមន្ត្រីការពារជាតិអាស៊ាន (ADSOM WG) នៅទីស្តីការក្រសួងការពារជាតិ រាជធានីភ្នំពេញ។ កិច្ចប្រជុំនេះ ដឹកនាំដោយ**ឯកឧត្តម ឧត្តមសេនីយ៍ឯក ឡៃ ចិន្តា** អគ្គនាយករង អគ្គនាយកដ្ឋាននយោបាយ និងកិច្ចការបរទេស និងជាប្រធានក្រុមការងារឧត្តមមន្ត្រីការពារជាតិអាស៊ានរបស់កម្ពុជា ដើម្បីពិភាក្សាលើឯកសារសំខាន់ៗសម្រាប់កិច្ចប្រជុំរដ្ឋមន្ត្រីការពារជាតិអាស៊ានឆ្នាំ២០២២ ក្រោមមូលបទ "**សាមគ្គីភាពដើម្បីសន្តិសុខប្រកបដោយភាពសុខដុម**"។

ក្នុងដំណើរការនៃកិច្ចប្រជុំ ក្រុមការងារឧត្តមមន្ត្រីការពារជាតិអាស៊ានបានស្តាប់របាយការណ៍អំពីវឌ្ឍនភាព និងការវាយតម្លៃអំពីដំណើរការនៃកិច្ចសហប្រតិបត្តិការការពារជាតិ ក្នុងក្របខ័ណ្ឌកិច្ចប្រជុំរដ្ឋមន្ត្រីការពារជាតិអាស៊ាន ដែលមានស្រាប់។

អង្គប្រជុំក៏បានពិភាក្សា និងឯកភាពលើឯកសារទស្សនទានចំនួនបីដែលផ្តួចផ្តើមដោយកម្ពុជា ក្នុងគោលដៅពង្រឹងកិច្ចសហប្រតិបត្តិការការពារជាតិរវាងបណ្តាប្រទេសជាសមាជិកអាស៊ាន ក្នុងវិស័យដូចជា ១) **ការលើកកម្ពស់កិច្ចសហប្រតិបត្តិការកងទ័ពបណ្តាប្រទេសអាស៊ានក្នុងការទប់ស្កាត់ជំងឺរាតត្បាតជំងឺឆ្លងដែន** ២) **ការលើកកម្ពស់យន្តការគាំទ្រសម្រាប់ស្ត្រីរក្សាសន្តិភាពអាស៊ាន** ៣) **ការបង្កើតកិច្ចសហការរវាងស្ថាប័នអប់រំយោធាអាស៊ាន** ដែលគំនិតផ្តួចផ្តើមទាំងនេះ នឹងត្រូវដាក់ជូនកិច្ចប្រជុំឧត្តមមន្ត្រីការពារជាតិអាស៊ានសម្រេច មុននឹងដាក់ជូនកិច្ចប្រជុំរដ្ឋមន្ត្រីការពារជាតិអាស៊ានអនុម័ត នៅក្នុងខែមិថុនា ឆ្នាំ២០២២។

ទន្ទឹមនេះ អង្គប្រជុំបានពិភាក្សាយ៉ាងល្អិតល្អន់ និងឯកភាពទៅលើខ្លឹមសារនៃ ១) **សេចក្តីប្រកាសរួមនៃកិច្ចប្រជុំរដ្ឋមន្ត្រីការពារជាតិអាស៊ាន** និង ២) **សេចក្តីប្រកាសរួមនៃកិច្ចប្រជុំរដ្ឋមន្ត្រីការពារជាតិអាស៊ានបូក** ដែលឯកសារទាំងពីរនេះនឹងត្រូវអនុម័តដោយកិច្ចប្រជុំរដ្ឋមន្ត្រីការពារជាតិអាស៊ាន ផងដែរ។

អង្គប្រជុំបានពិភាក្សា និងឯកភាពលើ **ចក្ខុវិស័យទីក្រុងភ្នំពេញ ស្តីពីតួនាទីនៃស្ថាប័នការពារជាតិក្នុងការគាំទ្រការស្តារឡើងវិញក្រោយកូវីដ១៩** ដែលបានសហការរៀបចំដោយកម្ពុជា និងសិង្ហបុរី ក្នុងគោលដៅបញ្ជាក់ពីគោលជំហររួមរបស់អាស៊ាន ក្នុងការពង្រឹងកិច្ចសហប្រតិបត្តិការរវាងស្ថាប័នការពារជាតិអាស៊ាន ដើម្បីលើកកម្ពស់សមត្ថភាពឆ្លើយតបទៅនឹងជំងឺរាតត្បាតកូវីដ១៩ឱ្យបានទាន់ពេលវេលា និងប្រកបដោយប្រសិទ្ធិភាព ព្រមទាំងដើម្បីគាំទ្រដល់កិច្ចខិតខំប្រឹងប្រែងក្នុងតំបន់ក្នុងការស្តារឡើងវិញបន្ទាប់ពីជំងឺរាតត្បាត។ ជាមួយគ្នានេះ អង្គប្រជុំក៏បានពិភាក្សាផងដែរ លើលក្ខខ័ណ្ឌប្រតិបត្តិនៃមជ្ឈមណ្ឌលឧត្តមភាពសន្តិសុខបច្ចេកវិទ្យាព័ត៌មានវិទ្យា និងព័ត៌មាន ដែលរៀបចំឡើងដោយប្រទេសសិង្ហបុរី។

ក្នុងនាមជាប្រធានក្រុមការងារឧត្តមមន្ត្រីការពារជាតិអាស៊ាន អគ្គនាយកដ្ឋាននយោបាយ និងកិច្ចការបរទេស ក្រសួងការពារជាតិ នឹងរៀបចំកិច្ចប្រជុំក្រុមការងារឧត្តមមន្ត្រីការពារជាតិអាស៊ានមួយលើកទៀត ក្នុងទម្រង់ជា Videoconference នៅក្នុងខែមីនា ឆ្នាំ២០២២ ខាងមុខ ដើម្បីពិភាក្សាបញ្ចប់ទាំងស្រុងនូវឯកសារដែលនៅសេសសល់ ដោយក្នុងនោះរួមមានឯកសារពិភាក្សាចំនួនពីរដែលផ្តួចផ្តើមដោយកម្ពុជា។

កិច្ចប្រជុំក្រុមការងារឧត្តមមន្ត្រីការពារជាតិអាស៊ាន បានបញ្ចប់ដោយទទួលបានលទ្ធផលល្អប្រសើរ ស្របតាមទិសដៅនៃការជម្រុញសាមគ្គីភាពក្នុងចំណោមបណ្តាប្រទេសជាសមាជិកអាស៊ាន ដើម្បីលើកកម្ពស់សន្តិសុខប្រកបដោយភាពសុខដុម។

ថ្ងៃពុធ ០៨កើត ខែមាឃ ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥
រាជធានីភ្នំពេញ ថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០២២